**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ក្រុមប្រឹក្សាជាតិគណនេយ្យ**

អគ្គនាយកដ្ឋានរតនាគារ
កាលបរិច្ឆេទ 08.11.11 ម៉ោង
លេខ 2484 ពជ.សារពី.
បញ្ជូនទៅ: - អគ្គនាយក
- ថ្នាក់នាយកដ្ឋាន
- ការិយាល័យ
ដើម្បី:
ហត្ថលេខា

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០១១

# សេចក្តីជូនដំណឹង

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ-ក្រុមប្រឹក្សាជាតិគណនេយ្យ មានកិត្តិយសសូមជូនដំណឹងដល់មន្ត្រីរាជការគ្រប់ក្រសួង/ស្ថាប័ន/អង្គភាព និងសាធារណៈ ជនឱ្យបានជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈក្រុមប្រឹក្សាជាតិគណនេយ្យ និងវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា នឹងផ្តល់អាហារូបករណ៍ចំនួន៧០ កន្លែងជូនដល់ពលរដ្ឋខ្មែរគ្រប់រូប (អ្នកបច្ចេកទេសគណនេយ្យ-CAT =៣៥ នាក់ និង គណនេយ្យករជំនាញ-ACCA/CPA =៣៥នាក់។ អាហារូបករណ៍នេះនឹងត្រូវផ្តល់ជូនតាមរយៈការប្រឡងប្រជែង ដែលនឹងប្រព្រឹត្តិទៅនៅថ្ងៃទី១៧-១៨ ខែធ្នូ ឆ្នាំ២០១១ ខាងមុខ។

**<u>លក្ខខណ្ឌសំរាប់និស្សិតថ្នាក់អ្នកបច្ចេកទេសគណនេយ្យ (Certified Accounting Technician-CAT)</u>**

- បានបញ្ចប់ឆ្នាំទី២ នៃថ្នាក់បរិញ្ញាបត្រនៃគ្រឹះស្ថានឧត្តមសិក្សាណាមួយ យ៉ាងទាបបំផុត
- មានចំណេះដឹងផ្នែកគណនេយ្យ/ហិរញ្ញវត្ថុ/ធនាគារ និងភាសាអង់គ្លេសច្បាស់លាស់

**<u>លក្ខខណ្ឌសំរាប់និស្សិតថ្នាក់គណនេយ្យករជំនាញ (Certified Public Accountants-CPA)</u>**

- មានបរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម/គណនេយ្យ/ហិរញ្ញវត្ថុ/ធនាគារ/សេដ្ឋកិច្ច/ច្បាប់/ព័ត៌មានវិទ្យា ឬសញ្ញាបត្រសមមូល
- មានចំណេះដឹងនិងបទពិសោធន៍ខាងគណនេយ្យ ហិរញ្ញវត្ថុ និងមានចំណេះដឹងភាសាអង់គ្លេសច្បាស់លាស់

**វិញ្ញាសាប្រឡងរួមមាន: គណនេយ្យ គណិតវិទ្យា និងភាសាអង់គ្លេស (បែប TOEFL)**

ប្រសិនបើសាធារណៈជនដែលមានលក្ខណៈសម្បត្តិដូចបានជំរាបខាងលើ មានបំណងចង់ប្រឡងយកអាហារូបករណ៍នេះ សូមអញ្ជើញមកទាក់ទង ដើម្បីសាកសួរព័ត៌មានបន្ថែម និងទទួលពាក្យប្រឡងនៅអគារក្រុមប្រឹក្សាជាតិគណនេយ្យ ដែលឋិតនៅក្នុងបរិវេណក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាសយដ្ឋានផ្លូវលេខ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ទូរស័ព្ទលេខ: 023 991036៕

- បេក្ខជនទាំងឡាយណាដែលបានចុះឈ្មោះនៅ ACCA រួចហើយ ពុំអាចទទួលបានអាហារូបករណ៍នេះឡើយ
- ចាប់ផ្តើមទទួលពាក្យប្រឡងចាប់ពីថ្ងៃផ្សាយដំណឹងនេះតទៅ រហូតដល់ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ វេលាម៉ោង ១៧ រសៀល៕

**រដ្ឋលេខាធិការ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ**

**ជី_តាមី**

***<u>ចំលងជូន:</u>***

-គ្រប់នាយកដ្ឋាន/អង្គភាព នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-គ្រប់ក្រសួង-ស្ថាប័ន

***ដើម្បីជូនជ្រាប និងផ្សព្វផ្សាយ***

ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៩៩១ ០៣៦ , ទូរសារ : ៨៥៥-២៣ ៩៩០ ៦៦៣
Phone: 855-23-991 036 , Fax: 855-23-990 663